សួស្តីមិត្តភក្តិទាំងអស់គ្នា ជួបជាមួយខ្ញុំម្តងទៀតហើយ ក្នុងការបកស្រាយនូវប្រធានបទមួយ ដែលមានចំណងជើងថា ម្ហូបហឹរ។ បាទ ដូច្នេះកុំឲ្យខាតពេលយូរ ខ្ញុំសូមបកស្រាយទៅលើម្ហូបហឹរនេះតែម្តង។ បាទ ម្ហូបហឹរ បាទ កាលណាដែលម្ហូបនោះគេធ្វើលក្ខណៈដូចជាឆ្ងាញ់ ឧទាហរណ៍ ដូចជាម្ហូបឆាគ្រឿងជាមួយគ្រំ បាទ ឆាគ្រឿងជាមួយគ្រំ បាទ ពេលដែល ដោយថាឆាមកអញ្ចឹងទៅ គេឲ្យញ៉ាំជាមួយបាយ បាទ ឆាមកជាមួយគ្រំ។ ហើយគ្រំនោះដែរ គឺយើងអាចរកបាននៅក្នុងទឹក វារស់នៅក្នុងទឹក ហើយវាមានលក្ខណៈកប់ភក់ វាមានរូបរាង ដោយថា វាជាពពួកសត្វអត់ឈាមដែរ។ បាទ ហើយវារស់នៅក្រោមទឹក ប៉ុន្តែវាមិនមែនងាវ ហើយក៏វាមិនមែនខ្យងដែរ។ វាគ្រាន់តែពពួកនៅជាមួយក្រុមតែមួយ ប៉ុន្តែវាមានរូបរាងខុសៗគ្នា។ បាទ វានៅក្នុងភក់អញ្ចឹងទៅ យើងយកដៃផ្ទះវាមកអញ្ចឹងទៅ បានប្រហែលជា ៣០ ឬមួយគឺ ៤០ អញ្ចឹងទៅ យើងយកមកឆាគ្រឿង បាទ ដែលឆាគ្រឿងនឹងយើងយកវាគ្រឿងមកផ្សំដូចជា គល់ស្លឹកគ្រៃ ដូចជារមៀត បាទ ដូចជាស្លឹកក្រូចសើច ដូចជាស្លឹកគ្រៃអីអញ្ចឹងទៅ។ បាទ ហើយពេលដែលយើងយកមក យើងបុកវាទៅ យើងយកវាឲ្យមកបុកចូលគ្នាអញ្ចឹងទៅ យើងបុក[ឲ្យ ?]គ្រឿង[... ?] យើងមិនមែនយកសាច់នឹងមកបុកនោះទេ។ បាទ យើងបុកវាចូលគ្នាអញ្ចឹងទៅ ហើយយើងដាក់ម្ទេសនឹងចូលដែរ យើងហាន់ម្ទេសនឹងឲ្យស្តើងៗ ហើយយើងយកវាទៅដាក់ជាមួយគ្រឿងហ្នឹង។ ពេលដែលសាច់គ្រំនោះវាឆ្អិនអស់ហើយ បាទ សាច់គ្រំនឹងដែលភាសា សាច់គ្រំនឹងដែលភាសាខ្មែរយើងគេហៅថា សាច់គ្រំអញ្ចឹង [កាលបើ ?]ខ្ញុំនៅស្រុកស្រែដល់ ពេលមកនៅក្រុង [...] គេហៅថាអយស្ទ័រ។ បាទ ពេលដែលវាឆ្អិនសព្វគ្រប់អស់ហើយ វាមានសូម្បីតែផ្សែងវាក៏មានលក្ខណៈថាឆួលដែរ។ ឆួលច្រមុះរបស់យើង ឆួលច្រមុះរបស់យើង វាធ្វើឲ្យយើងឆួលហើយ វាធ្វើឲ្យយើង [... ?]។ បាទ ហើយវាធ្វើឲ្យយើងនឹងឆួលច្រមុះតែម្តង អាចំហាយម្ទេសហ្នឹង។ បាទ ពេលដែលគេលើកមកហើយ គឺយើងត្រូវញ៉ាំហើយ បាទ យើងញ៉ាំ[ជា]មួយបាយអីអញ្ចឹងទៅ [...] ដល់ពេលយើងញ៉ាំ[ជា]មួយបាយ កាលណាដែលយើងញ៉ាំ[ជា]មួយបាយ គឺបាយវាមានលក្ខណៈក្តៅ បាទ បាយគឺមានលក្ខណៈក្តៅ ហើយពេលដែលយើងញ៉ាំអាម្ហូបក្តៅ អាម្ហូបលាយជាមួយម្ទេសនឹងទៀតទៅ វាធ្វើឲ្យយើងនឹងកាន់តែក្តៅថែមទៀត។ បាទ វាធ្វើ ឲ្យយើងនឹងកាន់តែក្តៅថែមទៀត ហើយពេលដែលយើងខំប្រឹងញ៉ាំវា ខំប្រឹងញ៉ាំវា វាធ្វើ ឲ្យយើងហៀរសំបោរផង វាធ្វើឲ្យយើងចេញទឹកភ្នែកផង បាទ វាធ្វើឲ្យយើងក្តៅត្រចៀក ផង។ បាទ ហើយយើងខំប្រឹងញ៉ាំដែរ ប៉ុន្តែយើងញ៉ាំបានតិច។ បាទ ពេលដែលញ៉ាំហើយ [...] វាក្តៅ មាត់ពេក ដល់ពេលក្តៅមាត់ពេកអញ្ចឹងទៅ យើងទៅរត់រកទឹកកក បាទ យកទឹកកកយកមកញ៉ាំអញ្ចឹងទៅ ដើម្បី[បំបាត់ ?] បាទ ប្រសិនជាអ្នកខ្លះទៀតគេទៅញ៉ាំស្ករ បាទ គេទៅញ៉ាំស្ករ បាទ គេទៅញ៉ាំស្ករអញ្ចឹងទៅ ធ្វើឲ្យវាហ្នឹង ដោយថាធូរស្បើយ ហើយនៅពេលដែលយើងញ៉ាំចូលទៅខាងក្នុងពោះយើង[អញ្ចឹងទៅ ?] ក្តៅពេកអញ្ចឹងទៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏វាមិនសូវល្អដែរ។ វាធ្វើឲ្យគ្រឿងក្នុងរបស់យើងវាក្ដៅអីអញ្ចឹងទៅ បាទ ហើយ[កាលណាអញ្ចឹងទៅ?]ធ្វើឲ្យយើងឈឺពោះ បាទ ធ្វើឲ្យយើងឈឺពោះទៀត។ ហើយ[កាលណា?]យើងមានអារម្មណ៍ថាខឹង ពេលដែលម្ហូបដែលយើងចូលចិត្តអីអញ្ចឹង យើងញ៉ាំវាអត់បានច្រើន បាទ ព្រោះថា អញ្ចឹងទៅ គេដាក់ម្ទេសច្រើន ហើយយើងអត់សូវចេះញ៉ាំម្ទេស កាលណាដែលគេដាក់ម្ទេសច្រើន យើងញ៉ាំទៅវាអត់កើត។ បាទ អញ្ចឹងទៅ បាទ ដូច្នេះគឺម្ហូបហឹរនេះ គឺយើងអាស្រ័យលើអ្នកដាក់ដែរ។ បាទ វាមានន័យអញ្ចឹង វាមានន័យថាអាស្រ័យលើអ្នកដាក់ដែរ។ បើសិនជាអ្នកដាក់តិច គឺយើងអាចញ៉ាំបាន [ប៉ុន្តែ?]បើសិនជាអ្នកដាក់ច្រើន គឺវាមានលក្ខណៈហឹរកាន់តែខ្លាំង ហើយម្ហូបគឺកាលណាគេយកសម្រាប់មកក្លែម ឬមួយក៏កាលណា គឺគេយកមកសម្រាប់ញ៉ាំលេងធម្មតាជាមួយបាយអីអញ្ចឹង ធ្វើជាម្ហូបអីអញ្ចឹងទៅ បាទ ដូច្នេះខ្ញុំសូម បញ្ចប់នូវការបកស្រាយនូវប្រធានបទម្ហូបហឹរនេះតែត្រឹមនេះសិន បាទ សូមអរគុណ សូមជម្រាបលា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.